កាន់តែទុកចិត្ត កាន់តែធំធើង
ហត្ថាកសិករ លីមីតធីត
HATTHA KAKSEKAR LIMITED

# របាយការណ៍ត្រីមាសទី៤

ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

Subsidiary of krungsri bank
A member of MUFG, a global financial group

## ទស្សនវិស័យ និងបេសកកម្ម

| | |
|---|---|
| ទស្សនវិស័យ | ជាគ្រឹះស្ថានហិរញ្ញវត្ថុដែលទទួលបានការកោតសរសើរខ្ពស់ និងជាជម្រើសដែលអតិថិជនពេញចិត្ត តាមរយៈបុគ្គលិកប្រកបដោយវិជ្ជាជីវៈ។ |
| បេសកកម្ម | យើងផ្តល់ជូនអតិថិជននូវដំណោះស្រាយហិរញ្ញវត្ថុ ដែលគួរឱ្យជឿទុកចិត្ត ងាយស្រួល និងប្រកបដោយភាពច្នៃប្រឌិត តាមរយៈបច្ចេកវិទ្យាឌីជីថល ដែលនាំមកនូវបទពិសោធន៍ល្អៗដល់អតិថិជន។ យើងប្តេជ្ញាចូលរួមចំណែកដល់ការរីកចម្រើនរបស់អតិថិជន និងសង្គម ប្រកបដោយចេរភាព។ |

## តម្លៃស្នូល

| | |
|---|---|
| ស្មោះត្រង់ | យើងប្តេជ្ញាធ្វើអ្វីដែលល្អ ប្រកបដោយភាពស្មោះត្រង់ ត្រឹមត្រូវ តម្លាភាព ទទួលខុសត្រូវ និងវិជ្ជាជីវៈ។ |
| ឧត្តមភាព | យើងប្តេជ្ញាធ្វើការងារប្រកបដោយឧត្តមភាពជាមួយកម្រិតបទដ្ឋានកាន់តែខ្ពស់ ហើយយើងចាប់យកការផ្លាស់ប្តូរ និងភាពច្នៃប្រឌិត ផ្នែកបច្ចេកវិទ្យា ដើម្បីក្លាយជាអ្នកនាំមុខគេនៅក្នុងទីផ្សារ។ |
| គាំពារ | យើងជួយ និងយកចិត្តទុកដាក់ចំពោះអតិថិជន តាមរយៈការធ្វើការរួមគ្នាដើម្បីកសាងអនាគតឱ្យកាន់តែប្រសើរ។ |
| ថាមវន្ត | យើងមានសុទិដ្ឋិនិយម និងសេចក្តីស្វាហាប់ដើម្បីដឹកនាំ និងធ្វើការរួមគ្នាក្នុងបរិយាកាសបើកទូលាយដើម្បីសម្រេចគោលដៅរបស់យើង។ |
| សាមញ្ញ | យើងធ្វើអ្វីៗឱ្យមានលក្ខណៈសាមញ្ញ ងាយស្រួល និងសមស្របសម្រាប់អតិថិជនដោយផ្អែកលើតម្រូវការរបស់ពួកគាត់ជាអទិភាព។ |

# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ | ត្រីមាសទី៤ឆ្នាំ២០១៩ | ដំណាច់ការិយបរិច្ឆេទឆ្នាំ ២០១៨ |
|---|---|---|
| ទ្រព្យសកម្មសរុប (លានរៀល) | ៤ ៩៩៩ ៣២៣ | ៣ ៧១៦ ៩៦៦ |
| បំណុលសរុប (លានរៀល) | ៤ ២០៥ ៨២៣ | ៣ ០៤៨ ៩៩៦ |
| មូលធនសរុប (លានរៀល) | ៧៩៣ ៥០០ | ៦៦៧ ៩៧០ |
| **លទ្ធផលហិរញ្ញវត្ថុ** | **ត្រីមាសទី៤ឆ្នាំ២០១៩** | **ត្រីមាសទី៤ឆ្នាំ២០១៨** |
| ចំណូលសរុប (លានរៀល) | ១៦៥ ១១៤ | ១២៦ ២២៥ |
| ចំណេញ/(ខាត)មុនបង់ពន្ធ (លានរៀល) | ៤២ ២៥៩ | ២៧ ២៦០ |
| ចំណេញ/(ខាត)សុទ្ធក្នុងការិយបរិច្ឆេទ (លានរៀល) | ៣៣ ៣៨៤ | ២១ ៧១៥ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ (លានរៀល) | ៣១ ៧៦៥ | ១៦ ២២១ |
| **អនុបាតហិរញ្ញវត្ថុ** | **ត្រីមាសទី៤ឆ្នាំ២០១៩** | **ដំណាច់ការិយបរិច្ឆេទឆ្នាំ ២០១៨** |
| អនុបាតសាធនភាព (ភាគរយ) | ១៩,៤ | ២០,០ |
| អនុបាតបំណុលធៀបនឹងមូលធន (ភាគរយ) | ៥៣០ | ៤៥៦ |
| អនុបាតសន្ទនីយភាព (ភាគរយ) | ១១៣,៩ | ១៧៧,០ |
| អនុបាតឥណទានមិនដំណើរការ[1] (ភាគរយ) | ០,៣០ | ០,៦៧ |
| អនុបាតបញ្ញើឥណទាន (ភាគរយ) | ៥៧,០ | ៦៣,៤ |
| | **ត្រីមាសទី៤ឆ្នាំ២០១៩** | **ត្រីមាសទី៤ឆ្នាំ២០១៨** |
| អនុបាតចំណេញភាពធៀបនឹងទ្រព្យសកម្ម (ភាគរយ) | ០,៦៤ | ០,៤៤ |
| អនុបាតចំណេញភាពធៀបនឹងមូលធន (ភាគរយ) | ៤,០០ | ២,៤៣ |
| អនុបាតលទ្ធភាពបង់ការប្រាក់ (ភាគរយ) | ១៦៦ | ១៥២ |



[1] និយមន័យរបស់ធនាគារជាតិនៃកម្ពុជា

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប






# សមាសភាពក្រុមប្រឹក្សាភិបាល



លោក **Dan Harsono**
ប្រធានក្រុមប្រឹក្សាភិបាល



លោក **ហួត អៀងតុង**
អភិបាល



កញ្ញា **Duangdao Wongpanitkrit**
អភិបាល



លោក **Rohit Khanna**
អភិបាល



លោក **Chandrashekar S.K.**
អភិបាល



លោក **Wanchairabin Jitwattanatam**
អភិបាល



លោក ឡូញ ហៃ
អភិបាលឯករាជ្យ



លោក ឌី ដាវុឌ្ឍ
អភិបាលឯករាជ្យ



លោក ប៉ាក សេរីវឌ្ឍនា
អភិបាលឯករាជ្យ

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

ក្នុងនាមជាស្ថាប័នបោះផ្សាយមូលបត្របំណុលសាជីវកម្មដំបូងបង្អស់នៅកម្ពុជា តាំងពី ខែ វិច្ឆិកា ឆ្នាំ ២០១៨ ជាមួយនឹងទឹកប្រាក់ចំនួន ១២០ ប៊ីលានរៀល (៣០ លានដុល្លារអាមេរិក) ហត្ថាកសិករលីមីតធីត មានមោទកភាពដែលបានបោះជំហានមុនគេក្នុងការលើកកម្ពស់ទីផ្សារមូលបត្របំណុលកម្ពុជាក៏ដូចជារូបិយវត្ថុប្រាក់រៀល។ ឆ្លៀតក្នុងឱកាសនេះយើងសូមជម្រាបជូនដល់សាធារណជន និងដៃគូពាណិជ្ជកម្មឱ្យបានជ្រាបពីវឌ្ឍនភាព និងបច្ចុប្បន្នភាពនៃព្រឹត្តិការណ៍មួយចំនួនក្នុងត្រីមាសទី ៤ ឆ្នាំ ២០១៩ដូចខាងក្រោមៈ

- ជម្រុញការផ្សព្វផ្សាយលើកកម្ពស់ឥណទានប្រាក់រៀលទៅកាន់អតិថិជន ដែលជាលទ្ធផលសម្រេចបាន ១៥.២៥% នៃផលប័ត្រឥណទានសរុប
- ផ្តល់ជូននូវផលិតផលឥណទាន "ហត្ថា First Choice" ដែលជាសេវាឥណទានមានលក្ខណៈល្អប្រសើរបំផុតសម្រាប់អតិថិជនដែលត្រូវការទិញសម្ភារប្រើប្រាស់ដូចជា ទូរស័ព្ទ ផលិតផលអេឡិចត្រូនិច និងឧបករណ៍ប្រើប្រាស់ក្នុងផ្ទះ ។
- ត្រៀមខ្លួនរួចជាស្រេចក្នុងការផ្តល់ជូនផលិតផលថ្មី នៅក្នុងខែ មករា ឆ្នាំ ២០២០ គឺឥណទាន "Auto Loan" ដែលជាសេវាឥណ-ទានមានលក្ខណៈល្អប្រសើរបំផុតសម្រាប់អតិថិជនដែលត្រូវការទិញយានយន្តប្រើប្រាស់ ។
- បង្កើតយុទ្ធនាការ ខ្ញុំស្រលាញ់ហត្ថាកសិករ (I LOVE HKL) ដើម្បីលើកកម្ពស់ការយល់ដឹងលើស្លាកសញ្ញា និងបង្កើនការយល់ដឹងអំពីទស្សនវិស័យ បេសកកម្ម តម្លៃស្នូល និង អត្តសញ្ញាណថ្មីរបស់ក្រុមហ៊ុន។ យើងជឿជាក់ថា តាមរយៈយុទ្ធនាការនេះ បុគ្គលិករបស់យើងនឹងកាន់តែផ្សារភ្ជាប់ល្អជាមួយស្ថាប័ន ហើយនេះគឺជាការជម្រុញបន្ថែមដល់ការអនុវត្តយុទ្ធសាស្ត្រអាជីវកម្មរបស់យើងឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់មួយកម្រិតទៀត។

នៅត្រីមាសទី ៤ ឆ្នាំ ២០១៩ យើងបានបន្តដំណើរការអាជីវកម្មរឹងមាំ ខណៈពេលដែលការជំរុញស្តង់ដារកែលម្អប្រតិបត្តិការរបស់យើងឆ្ពោះទៅកាន់ស្តង់ដារធនាគារជាពិសេសយើងតែងតែយកចិត្តទុកដាក់ ក្នុងការផ្តល់សេវាកម្មទូទៅ ពិសេសសេវាឥណទានប្រកបដោយតម្លាភាព និងយ៉ាងសម្បូរបែប។ គិតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩ ហត្ថាកសិករលីមីតធីត មានផលប័ត្រឥណទានចំនួន ១០៥១ លានដុល្លារអាមេរិក ជាមួយកំណើនវិជ្ជមាន ១១% បើធៀបនឹងត្រីមាសមុន។ យើងនៅតែបន្តបម្រើសេវាទៅកាន់អតិថិជនទាំងជាលក្ខណៈបុគ្គល និងអាជីវកម្មខ្នាតតូចបានយ៉ាងល្អប្រសើរជាមួយនឹងបណ្តាញដ៏រឹងមាំរបស់យើងនៅទូទាំងប្រទេស ដែលបានធ្វើឱ្យជីវភាពរស់នៅ ក៏ដូចជាលទ្ធផលអាជីវកម្មរបស់ពួកគេកាន់តែប្រសើរឡើងថែមទៀត។ ក្នុងនោះ ផលប័ត្រឥណទានយឺតយ៉ាវ (៣០ថ្ងៃ) ត្រូវបានគ្រប់គ្រងបានយ៉ាងល្អប្រសើរគឺស្ថិតក្នុងកម្រិតទាបត្រឹមតែ ០.៣៧% ។ ប្រាក់បញ្ញើសន្សំបានកើនឡើងដល់ ៥៩៩ លានដុល្លារអាមេរិកជាមួយអត្រាកំណើន ២.៥៧% ធៀបនឹងត្រីមាសមុន។ លទ្ធផលអាជីវកម្មទូទៅបានបង្ហាញពីជំហរល្អជាងឆ្នាំមុន។ ចំនួនបុគ្គលិករបស់យើងកើនឡើងដល់ ៤៣៨២នាក់ ដែលពោរពេញដោយសមត្ថភាពក្នុងការផ្តល់ការរីកចម្រើនដល់ស្ថាប័ន និងអតិថិជន។

ឆ្នាំចាស់បានកន្លងផុតទៅជាមួយនឹងកំណត់ត្រាអាជីវកម្មគួរជាទីគាប់ចិត្ត។ ឆ្លៀតក្នុងឱកាសនេះផងដែរ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ និយ័តករ អតិថិជន និងភាគីពាក់ព័ន្ធទាំងអស់ដែលបានគាំទ្រ និងជឿជាក់លើស្ថាប័នរបស់យើង។ ស្របតាមការប្តេជ្ញា និងទស្សនវិស័យរបស់ស្ថាប័នយើង ក្នុងឆ្នាំ ២០២០ ខាងមុខនេះ យើងនឹងបន្តជម្រុញបន្ថែមទៀតនូវសកម្មភាពគោលសំខាន់ៗ ដើម្បីធានាបានថា ហត្ថាកសិករលីមីតធីត គឺជាស្ថាប័នហិរញ្ញវត្ថុដែលមានការកោតសរសើរខ្ពស់ជាងគេនៅកម្ពុជា។

កាលបរិច្ឆេទៈ ២១-កុម្ភៈ-២០២០

ហត្ថលេខា និង ត្រា

ហត្ថាកសិករ លីមីតធីត ការិយាល័យកណ្តាល HKL Head Office HATTHA KAKSEKAR LIMITED

លោក Dan Harsono

ប្រធានក្រុមប្រឹក្សាភិបាល

# សេចក្តីថ្លែងរបស់ប្រធានអគ្គនាយក

ដោយមានការខិតខំប្រឹងប្រែងបំពេញការងាររួមគ្នាពីសំណាក់បុគ្គលិក និងគណៈគ្រប់គ្រងរបស់ខ្លួន ព្រមទាំងម្ចាស់ភាគហ៊ុនជាធនាគារ Ayudhya ឈានមុខគេមួយនៅក្នុងប្រទេសថៃ និងជាសមាជិករបស់ MUFG ហត្ថាកសិករ លីមីតធីត បានត្រៀមខ្លួនរួចជាស្រេច ទាំងធនធានមនុស្ស ទាំងដើមទុន និងបច្ចេកវិទ្យាព័ត៌មាន ក្នុងការក្លាយខ្លួនទៅជាធនាគារពាណិជ្ជ ដើម្បីបម្រើសេវាកម្ម និង ផលិតផលហិរញ្ញវត្ថុប្រកបដោយភាពស្មោះត្រង់ សាមញ្ញ និងមានវិជ្ជាជីវៈ ជាមួយនឹងទស្សនវិស័យឌីជីថលកាន់តែទំនើបដល់អតិថិជន។

ហត្ថាកសិករលីមីតធីត សូមប្រកាសបង្ហាញនូវសមិទ្ធផលគិតត្រឹមខែធ្នូ ឆ្នាំ២០១៩ មានអតិថិជនឥណទានសរុបរបស់យើងចំនួនជាង ១៦៨ ៨៩២នាក់ អតិថិជនដាក់ប្រាក់បញ្ញើសន្សំចំនួនជាង ២៥៩ ៦៣៤ នាក់ និង អតិថិជនប្រើប្រាស់ប័ណ្ណអេធីអឹមចំនួនជាង ៥១ ១៦២នាក់។ ផលប័ត្រឥណទាន បានឈានដល់ ១ ០៥១ លានដុល្លារអាមេរិក ស្របពេលទទួលបានកំណើននៃប្រាក់ចំណេញសុទ្ធគួរឱ្យកត់សម្គាល់ផងដែរ។ ចំនួនប្រាក់បញ្ញើសន្សំ បានកើនឡើងដល់ ៥៩៩លានដុល្លារអាមេរិក ដែលបង្ហាញពីទំនុកចិត្តខ្ពស់បំផុតពីអតិថិជន និងសាធារណជនមកកាន់ហត្ថាកសិករ លីមីតធីត ។

ប្រតិបត្តិការរបស់ហត្ថាកសិករលីមីតធីត ត្រូវបានពង្រីកដល់ ១៧៧សាខា ជាមួយនឹងម៉ាស៊ីន ATM ចំនួន១៣៧ នៅទូទាំងប្រទេស។ បុគ្គលិករបស់យើងមានចំនួនសរុប ៤ ៣៨២នាក់ កំពុងផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុដ៏ល្អបំផុត តាមរយៈបណ្តាញសាខាយ៉ាងធំទូលំទូលាយទូទាំងផ្ទៃប្រទេស។

នៅក្នុងផ្នែកឌីជីថល ហត្ថាកសិករលីមីតធីត នៅតែបន្តនាំយកបច្ចេកវិទ្យាជឿនលឿនថ្មីៗ និងទាញជាប្រយោជន៍សម្រាប់គ្រប់សកម្មភាពប្រតិបត្តិការទាំងអស់ ដើម្បីឆ្លើយតបតម្រូវការរបស់អតិថិជនឱ្យទទួលបាននិរន្តរភាពក្នុងសម័យឌីជីថលនេះ។ យើងបន្តពង្រីកប្រព័ន្ធធនាគារចល័តទាំងតាមរយៈទូរស័ព្ទ និងInternet ដើម្បីបម្រើអតិថិជនរបស់យើង ឱ្យបានកាន់តែប្រសើរឡើងតាមរយៈក្រុមការងារ ដែលមានបទពិសោធន៍ខ្ពស់។ មកដល់ពេលបច្ចុប្បន្ន អតិថិជនប្រើប្រាស់ប្រព័ន្ធធនាគារចល័តទាំងតាមរយៈទូរស័ព្ទ និង Internet មានចំនួនជាង ៨ ០២៤នាក់។ ហត្ថាកសិករលីមីតធីត ខិតខំផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុឈានមុខគេមួយ ដែលមានភាពងាយស្រួល និងទុកចិត្តបានដល់អតិថិជន។ នៅខែឧសភា ឆ្នាំ ២០១៨ ហត្ថាកសិករ លីមីតធីត ទទួលបានចំណាត់ថ្នាក់ «BBB+» ពីភ្នាក់ងារវាយតម្លៃអន្តរជាតិ TRIS ដែលបានបញ្ជាក់ពីប្រតិបត្តិការមានស្ថេរភាពជាមួយនឹងជំហររឹងមាំក្នុងទីផ្សារកម្ពុជា។ ចំណុចវាយតម្លៃរួមមានដូចជា បណ្តាញសាខាទូទាំងប្រទេស ភាពចម្រុះនៃប្រភេទអតិថិជន ប្រព័ន្ធគ្រប់គ្រងហានិភ័យល្អ, ការគ្រប់គ្រងហិរញ្ញវត្ថុ និងសាច់ប្រាក់រឹងមាំ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់គណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់ ដែលបានប្តេជ្ញាចិត្តធ្វើឱ្យសម្រេចសមិទ្ធផលដ៏អស្ចារ្យនេះ។ ខ្ញុំសូមកោតសរសើរ និងដឹងគុណចំពោះទំនុកចិត្ត និងការគាំទ្រពីសំណាក់អតិថិជន ដៃគូអាជីវកម្ម និងសាធារណជន ហើយខ្ញុំសង្ឃឹមនិងជឿជាក់ថា នឹងផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុស្តង់ដាខ្ពស់បំផុត ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ។

កាលបរិច្ឆេទ៖ ២៦-កុម្ភៈ-២០២០

ហត្ថលេខា

លោក ហួត អៀងតុង

ប្រធានអគ្គនាយក

# មាតិកា

ទស្សនវិស័យ និងបេសកកម្ម ........ i

តម្លៃស្នូល ........ i

ព័ត៌មានហិរញ្ញវត្ថុសង្ខេប ........ ii

ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប ........ iii

សមាសភាពក្រុមប្រឹក្សាភិបាល ........ iv

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ........ v

សេចក្តីថ្លែងរបស់ប្រធានអគ្គនាយក ........ vi

ផ្នែកទី ១ : ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីមូលបត្រ ........ ១

ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ ........ ១

ខ- លក្ខណៈនៃធុរកិច្ច ........ ១

គ. ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ........ ២

ផ្នែកទី ២ : ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ........ ២

ក.លទ្ធផលប្រតិបត្តិការធុរកិច្ច ........ ២

ខ-រចនាសម្ព័ន្ធចំណូល ........ ៣

ផ្នែកទី ៣ : របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករឯករាជ្យ ........ ៤

ផ្នែកទី ៤ : ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង ........ ៥

ក-ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ........ ៥

ខ-កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ........ ៥

គ-ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ........ ៥

ឃ-ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ........ ៥

ង-ផលប៉ះពាល់នៃអតិផរណា ........ ៦

ច-គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល ........ ៦

# ផ្នែកទី ១ : ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីមូលបត្រ

## ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | ហត្ថាកសិករលីមីតធីត |
| ឈ្មោះជាអក្សរឡាតាំង | Hattha Kaksekar Limited |
| អក្សរកូដ | HKL |
| អាសយដ្ឋាន | អគារលេខ ៦០៦ ផ្លូវ២៧១ ភូមិសន្សំកុសល ៣ សង្កាត់បឹងទំពន់ ទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ |
| លេខទូរស័ព្ទ | ០២៣ ៩៩៩ ៣០៤ |
| គេហទំព័រ | www.hkl.com.kh |
| អ៊ីម៉ែល | info@hkl.com.kh |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០០៥៣៥៥ (ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០១) |
| លេខអាជ្ញាបណ្ណអាជីវកម្ម | ម.ហ ០២-១២/០៦/១១/០១ ចេញដោយ: ធនាគារជាតិនៃកម្ពុជា កាលបរិច្ឆេទ: ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៧ |
| សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន | លេខ ១៦៥/១៨គ.ម.ក. កាលបរិច្ឆេទ: ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៨ |
| តំណាងHKLដោយ | លោក ហួត អៀងតុង |

## ខ- លក្ខណៈនៃធុរកិច្ច

ហត្ថាកសិករលីមីតធីត គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើសន្សំធំមួយ ទទួលបានអាជ្ញាប័ណ្ណ ពីធនាគារជាតិនៃកម្ពុជា និងបានធ្វើប្រតិបត្តិការជាង ២៥ឆ្នាំ មកហើយ។ ហត្ថាកសិករលីមីតធីត បាននឹងកំពុងផ្តល់សេវាកម្មហិរញ្ញវត្ថុយ៉ាងសម្បូរបែបដល់អតិថិជនដូចជា៖ សេវាឥណទាន សេវាប្រាក់បញ្ញើសន្សំ សេវាផ្ទេរប្រាក់ក្នុងស្រុកសេវាអេធីអឹម សេវាធនាគារចល័ត សេវាបើកប្រាក់បៀវត្ស និងជាអ្នកណែនាំលក់សេវាធានារ៉ាប់រងផងដែរ តាមរយៈសាខាចំនួន ១៧៧ និងម៉ាស៊ីនអេធីអឹមចំនួន ១៣៧ទីតាំងនៅទូទាំងប្រទេស។ គិតត្រឹមខែធ្នូ ឆ្នាំ ២០១៩ សមតុល្យប្រាក់បញ្ញើសន្សំ របស់ហត្ថាកសិករលីមីតធីត មានចំនួនជាង ៥៩៩ លានដុល្លារអាមេរិក ជាមួយនឹងចំនួនអតិថិជន ប្រាក់បញ្ញើសន្សំជាង ២៥៩ ៦៣៤នាក់ ជាមួយផលប័ត្រឥណទានសរុបមាន ចំនួនប្រមាណ ១ ០៥១ លានដុល្លារអាមេរិក ដែលបម្រើអតិថិជន ចំនួន ១៦៨ ៩៩២នាក់។ បច្ចុប្បន្ន ហត្ថាកសិករលីមីតធីត គឺជាបុត្រសម្ព័ន្ធរបស់ធនាគារ Krungsri ដែលជាធនាគារពាណិជ្ជធំជាងគេលំដាប់ទី ៥ នៅព្រះរាជាណាចក្រថៃ និងជាសមាជិករបស់សម្ព័ន្ធហិរញ្ញវត្ថុអន្តរជាតិ Mitsubishi UFJ Financial Group (MUFG) ដែលជាសម្ព័ន្ធធនាគារធំជាងគេបំផុតនៅប្រទេសជប៉ុន ព្រមទាំងជាសម្ព័ន្ធសេវាហិរញ្ញវត្ថុដ៏ធំមួយក្នុងចំណោម សម្ព័ន្ធហិរញ្ញវត្ថុ ធំជាងគេលើសកលលោក។

គ. ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

ក្នុងត្រីមាសនេះមានការសម្រេចបាននូវសមិទ្ធផល មួយចំនួនបន្ថែមដែលគួរឱ្យកត់សម្គាល់មានដូចជា៖

- ផ្តល់ជូននូវផលិតផលឥណទាន "ហត្ថា First Choice" ដែលជាសេវាឥណទានមានលក្ខណៈល្អប្រសើរបំផុតសម្រាប់អតិថិជនដែលត្រូវការទិញសម្ភារប្រើប្រាស់ដូចជា ទូរស័ព្ទ ផលិតផលអេឡិចត្រូនិច និងឧបករណ៍ប្រើប្រាស់ក្នុងផ្ទះ ។
- ត្រៀមខ្លួនរួចជាស្រេចក្នុងការផ្តល់ជូនផលិតផលថ្មី នៅក្នុងខែ មករា ឆ្នាំ ២០២០ គឺឥណទាន "Auto Loan" ដែលជាសេវាឥណទានមានលក្ខណៈល្អប្រសើរបំផុតសម្រាប់អតិថិជនដែលត្រូវការទិញយានយន្តប្រើប្រាស់ ។
- ការសម្រេចបាននូវផលប័ត្រកម្ចីបានរហូតដល់១០៥១ លាន ដុល្លារ រួមជាមួយការកម្ពស់ឥណទានប្រាក់រៀលទៅកាន់អតិថិជនបានរហូតដល់ ១៥.២៥%
- បង្កើតយុទ្ធនាការ ខ្ញុំស្រលាញ់ហត្ថាកសិករ (I LOVE HKL) ដើម្បីលើកកម្ពស់ការយល់ដឹងលើស្លាកសញ្ញា និងបង្កើនការយល់ដឹងអំពីទស្សនវិស័យ បេសកកម្ម តម្លៃស្នូល និង អត្តសញ្ញាណថ្មីរបស់ក្រុមហ៊ុន។ យើងជឿជាក់ថា តាមរយៈយុទ្ធនាការនេះ បុគ្គលិករបស់យើងនឹងកាន់តែផ្សារភ្ជាប់ល្អជាមួយស្ថាប័ន ហើយនេះគឺជាការជម្រុញបន្ថែមដល់ការអនុវត្តយុទ្ធសាស្រ្តអាជីវកម្មរបស់យើងឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់មួយកម្រិតទៀត។

## ផ្នែកទី ២ : ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

### ក. លទ្ធផលប្រតិបត្តិការធុរកិច្ច

| លទ្ធផលសម្រេចបានសំខាន់ៗ នាខែធ្នូ ឆ្នាំ២០១៩ | ផែនការ | លទ្ធផលសម្រេចបាន |
|---|---|---|
| ផ្នែកសេវាឥណទាន | | |
| ចំនួនគណនីសេវាឥណទាន | ១៥៨ ០០០ | ១៦៨ ៨៩២ |
| ឥណទាននៅក្នុងដៃអតិថិជន (ពាន់ដុល្លារអាមេរិក) | ៩៤៩ ៩៩១ | ១ ០៥០ ៩២៩ |
| ផ្នែកសេវាប្រាក់បញ្ញើសន្សំ | | |
| ចំនួនគណនីសេវាប្រាក់បញ្ញើសន្សំ | ២៧១ ६៥៨ | ២៥៩ ៦៣៤ |
| សមតុលប្រាក់បញ្ញើសន្សំ (ពាន់ដុល្លារអាមេរិក) | ៥៧២ ៤៥២ | ៥៩៩ ៣០២ |
| ផ្នែកសេវាកម្មផ្សេងៗទៀត | | |
| ចំនួនអ្នកប្រើប្រាស់កាតអេធីអឹម | ៥៧ ៧៣៩ | ៥១ ១៦២ |
| ចំនួនអ្នកប្រើប្រាស់សេវាធនាគារចល័ត | ៨ ៨១៥ | ៨ ០២៤ |
| ការណែនាំភ្ញៀវឱ្យប្រើប្រាស់សេវាធានារ៉ាប់រងខ្នាតតូច (ដុល្លារអាមេរិក) | ៦៣២ ៨៥៩ | ៥១២ ៥៣៣ |

| | | |
|---|---|---|
| ការណែនាំភ្ញៀវឱ្យប្រើប្រាស់សេវាធានារ៉ាប់រងអាយុជីវិតឥណទាន (ដុល្លារអាមេរិក) | ១ ៦៥១ ០១១ | ៤ ៨២៨ ១៨៩ |
| ផ្នែកប្រតិបត្តិការសំខាន់ផ្សេងៗទៀត | | |
| ចំនួនការិយាល័យ | ១៧៨ | ១៧៧ |
| ចំនួនអេធីអឹម | ១៣៩ | ១៣៧ |
| ចំនួនបុគ្គលិក | ៤ ២៧៤ | ៤ ៣៨២ |

## ខ-រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល | ត្រីមាសទី៤ ឆ្នាំ ២០១៩ | | ត្រីមាសទី៤ ឆ្នាំ ២០១៨ | |
|---|---|---|---|---|---|
| | | ចំនួនទឹកប្រាក់ (លានរៀល) | ភាគរយ | ចំនួនទឹកប្រាក់ (លានរៀល) | ភាគរយ |
| ១ | ចំណូលការប្រាក់ | ១៦០ ៥៥៥ | ៩៧,២ | ១២១ ៤៧៦ | ៩៦,២ |
| ២ | ចំណូលផ្សេងៗ | ៤ ៥៥៩ | ២,៨ | ៤ ៧៤៩ | ៣,៨ |
| | ចំណូលសរុប | ១៦៥ ១១៤ | | ១២៦ ២២៥ | |

# ផ្នែកទី ៣ : របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករឯករាជ្យ

សូមពិនិត្យមើលរបាយការណ៍លម្អិតនៅក្នុងឧបសម្ព័ន្ធដែលបានភ្ជាប់មកជាមួយ។

## ផ្នែកទី ៤: ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងការវិភាគខាងក្រោមនេះ គឺជាការពិភាក្សាលើលទ្ធផលនៃប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុដោយ គណៈគ្រប់គ្រងរបស់ ហត្ថាកសិករលីមីតធីត ដោយផ្អែកទៅលើរបាយការណ៍ហិរញ្ញវត្ថុគិតត្រឹម ថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ ២០១៩ ហើយដែលបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ គិតត្រឹមថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ ២០១៩។

របាយការណ៍ហិរញ្ញវត្ថុទាំងនេះរបស់ហត្ថាកសិករលីមីតធីតត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ។

គណៈគ្រប់គ្រងធ្វើការពិភាក្សា និងវិភាគលើសមាសធាតុសំខាន់នៃរបាយការណ៍ហិរញ្ញវត្ថុ និងកត្តាសំខាន់ៗដែលបាន ជះឥទ្ធិពលទៅលើប្រាក់ចំណេញរបស់ហត្ថាកសិករលីមីតធីតតែប៉ុណ្ណោះ ។

### ក-ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

#### ការវិភាគចំណូល

ហត្ថាកសិករលីមីតធីតមានចំណូល ២ប្រភេទធំៗគឺ ចំណូលពីការប្រាក់ និងចំណូលផ្សេងៗ

| | |
|---|---|
| **ចំណូលពីការប្រាក់រួមមាន៖** ចំណូលការប្រាក់សុទ្ធដែលទទួលបានពីការផ្តល់ឥណទានដល់ អតិថិជន និងពីការដាក់ប្រាក់បញ្ញើនៅតាមបណ្តា ធនាគារនានា។ ហើយចំណូលទាំងនេះត្រូវទទួលស្គាល់ជាប្រចាំខែ។ | **ចំណូលផ្សេងៗរួមមាន៖** កម្រៃណែនាំសេវាធានារ៉ាប់រង កម្រៃផ្ទេរប្រាក់ ចំណូលកម្រៃផ្សេងៗ ចំណូលបានមកពីការប្រមូលឥណទានលុបចោល ចំណេញពីការប្តូរប្រាក់ ។ល។ |

ចំណូលការប្រាក់ ជាចំណូលដ៏ធំនិងសំខាន់សម្រាប់ ហត្ថាកសិករលីមីតធីតដែលមានរហូតដល់ ៩៧.២% នៃចំណូលសរុប។

### ខ-កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

នាដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ ២០១៩ នេះ គណៈគ្រប់គ្រង់យល់ថា ហត្ថាកសិករលីមីតធីត ពុំមានធាតុ ដែលខុសពីធម្មតាទេ។

### គ-ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

នាដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ ២០១៩នេះ គណៈគ្រប់គ្រងយល់ថា ហត្ថាកសិករលីមីតធីត ពុំមានធាតុដែលជាការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូលខុសពីធម្មតាទេ។

### ឃ-ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

ហត្ថាកសិករលីមីតធីត បានកត់ត្រាបញ្ជីគណនេយ្យដោយប្រើប្រាស់រូបិយប័ណ្ណគោលគឺ ប្រាក់ដុល្លារអាមេរិក។ ប្រតិបត្តិការជា រូបិយវត្ថុប្រាក់រៀល និងរូបិយប័ណ្ណប្រាក់ថៃបាត ត្រូវបានប្តូរទៅជា រូបិយប័ណ្ណគោលតាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និង ខាតដែលបណ្តាលមកពីការទូទាត់ប្រតិបត្តិការបែបនេះ ការប្តូរទ្រព្យសកម្មនិងបំណុល រូបិយប័ណ្ណបរទេស ត្រូវបានកត់ត្រា នៅក្នុងរបាយការណ៍លទ្ធផលលម្អិត។

**ង-ផលប៉ះពាល់នៃអតិផរណា**

ហត្ថាកសិករ លីមីតធីត មិនបានកែប្រែអត្រាការប្រាក់ដោយផ្អែកតាមការប្រែប្រួលនៃអតិផរណាទេ ពោលគឺផ្អែកទៅលើស្ថានភាព ប្រកួតប្រជែងជាក់ស្តែងនៅក្នុងទីផ្សារ ហើយនៅតែរក្សាបាននូវចេរភាពហិរញ្ញវត្ថុយ៉ាងល្អប្រសើរ។

**ច-គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល**

នៅត្រីមាសទី៤ ក្នុងឆ្នាំ២០១៩ ដើម្បីទាក់ទាញអ្នកវិនិយោគទុនក្រៅប្រទេសក៏ដូចជាការលើកទឹកចិត្តអ្នកវិនិយោគ-ទុននៅក្នុងប្រទេស និងដើម្បីជំរុញកំណើនសេដ្ឋកិច្ចជាតិឱ្យរីកលូតលាស់កាន់តែខ្លាំងបន្ថែមទៀត រាជរដ្ឋាភិបាលបានធ្វើការដាក់ចេញឱ្យអនុវត្តនូវគោលនយោបាយទាក់ទងនឹងវិស័យហិរញ្ញវត្ថុមួយចំនួនដូចជា៖

- រាជរដ្ឋាភិបាលបានអនុម័តទាំងស្រុង លើសេចក្តីព្រាងច្បាប់ស្តីពី ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក្នុងគោលបំណងផ្តល់ជាវិធានមូលដ្ឋានដ៏សំខាន់ ក្នុងការជំរុញពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកទាំងក្នុង និងក្រៅប្រទេសប្រកបដោយទំនុកចិត្ត ដែលសេចក្តីព្រាងច្បាប់នេះ នឹងរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលនៅកម្ពុជា។
- រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយជាតិស្តីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ភាពឆ្នាំ២០២០-២០៣០ ក្នុងគោលបំណងពង្រឹងមូលដ្ឋានគ្រឹះ និងកែលម្អបរិយាកាសនៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីអភិវឌ្ឍប្រកបដោយចីរភាព និងលើកកម្ពស់គុណភាពជីវិតប្រជាជនឲ្យកាន់តែប្រសើរ និងអភិវឌ្ឍប្រព័ន្ធអេកូនវានុវត្តន៍នៅគ្រប់កម្រិត និងគ្រប់វិស័យ។

ហត្ថលេខារបស់អភិបាលហត្ថាកសិករ លីមីតធីត បានអាននិងឯកភាព នៅថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ២០២០។

| | |
|---|---|
| លោក ឡូញ ហៃ | លោក ឌី ដាវុឌ្ឍ |
| អភិបាលឯករាជ្យ | អភិបាលឯករាជ្យ |

កាន់តែទុកចិត្ត កាន់តែចំរើន

ហត្ថាកសិករ លីមីតធីត

HATTHA KAKSEKAR LIMITED

**Subsidiary of krungsri bank**

A member of MUFG, a global financial group